ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ: ៣៣៤.......... ប្រក.កសក

# ប្រកាស

## ស្តីពី

## ការត្រួតពិនិត្យសុវត្ថិភាពចំណីអាហារនៃផលិតផលកសិកម្ម

*****

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផលទំនិញ និងសេវា
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងសម្របសម្រួលការត្រួតពិនិត្យគុណភាព សុវត្ថិភាពផលិតផល និងសេវាកម្ម
- បានឃើញអនុក្រឹត្យលេខ ២៨ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ មិនា ឆ្នាំ ២០០១ កែសម្រួល និងបំពេញបន្ថែមអនុក្រឹត្យលេខ ០៥ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង សម្របសម្រួលការត្រួតពិនិត្យគុណភាព សុវត្ថិភាព ផលិតផលកសិកម្ម និងសេវាកម្ម
- បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០៣ ស្តីពីអនាម័យនៃម្ហូបអាហារសម្រាប់មនុស្ស

- បានឃើញអនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០៥ ស្តីពីការបន្ថែមមុខងារភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការ និងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្មចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១ .-**

ប្រកាសនេះមានគោលបំណងកំណត់គោលការណ៍ និងវិធានការសម្រាប់គ្រប់គ្រង ត្រួតពិនិត្យ ដើម្បីធានាសុវត្ថិភាព និងបមាណីចំណីអាហារនៃផលិតផលកសិកម្មទាំងអស់ ដែលមានទិសដៅសម្រាប់ធ្វើជាម្ហូបអាហាររបស់មនុស្ស ។

**ប្រការ ២ .-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះផលិតកម្មកសិកម្មទាំងអស់ ចាប់តាំងពីការផ្តើមផលិត ដាំដុះរហូតដល់ដំណាក់កាលចុងក្រោយនៃការកែច្នៃបឋម ។

**ប្រការ ៣ .-**

វាក្យស័ព្ទដែលប្រើក្នុងប្រកាសនេះត្រូវបានបកស្រាយដូចខាងក្រោម :

" ផលិតកម្មកសិកម្ម " សំដៅដល់រាល់ផលិតកម្មពីវិស័យកសិកម្មរួមមានជាអាទិ៍ ការដាំដុះ ការចិញ្ចឹមសត្វ វារីវប្បកម្ម មធុវប្បកម្ម( ការចិញ្ចឹមឃ្មុំ) កោសយ្យវប្បកម្ម( ការចិញ្ចឹមដង្កូវនាង ) ។ល។

" ផលិតផលកសិកម្ម " សំដៅដល់ផលិតផលនៃផលិតកម្មកសិកម្មទាំងអស់

" ចំណីអាហារនៃផលិតផលកសិកម្ម " សំដៅដល់ផលិតផលកសិកម្មទាំងអស់ តាំងពីដំណាក់កាលចាប់ផ្តើមពីផលិតកម្មដំបូងរហូតដល់ដំណាក់កាលចុងក្រោយនៃការកែច្នៃបឋមដែលយកទៅប្រើប្រាស់ ឬ យកទៅកែច្នៃជាចំណីអាហាររបស់មនុស្ស

" ការកែច្នៃបឋម " សំដៅដល់ការបំប្លែងវត្ថុធាតុដើមនៃផលិតផលកសិកម្ម តាមរយៈដំណើរនៃការកែច្នៃមានជាអាទិ៍ ការកិន ការសំអាត ការបកសំបក ឬ ចិតយកសំបកចេញ ការហាន់ ការបោកបែន ការរោយ ការពិឃាតសត្វ ការពន្លាត់ស្បែក ការធ្វើចំណាត់ថ្នាក់ ការវេចខ្ចប់ ការបាលសំងួត ការស្ងោរ ការប្រលាក់ ការផ្អាប់

ការឆ្អើរ ការបង្អក ការវេចខ្ចប់ ការរក្សាទុក ការដឹកជញ្ជូន ការកែច្នៃតាមបែបបុរាណ ឬ តាមបច្ចេកវិជ្ជាផ្សេងៗទៀតរហូតដល់ដំណាក់កាលចុងក្រោយបង្កើតបានជាផលិតផលកែច្នៃមិនទាន់សំរេចដែលត្រូវយកទៅប្រើប្រាស់ ឬយកទៅកែច្នៃបញ្ចប់ជាចំណីអាហារសម្រាប់មនុស្សបរិភោគ

" ចំណាត់ថ្នាក់ " សំដៅដល់ការបែងចែកផលិតផលកសិកម្ម ដោយផ្អែកលើលក្ខណៈរូប និងគុណភាពនៃផលិតផលទាំងនោះ

" ការវេចខ្ចប់ " សំដៅដល់ការការពារផលិតផលកសិកម្ម ដើម្បីរក្សាគុណភាព និងវិលេចសោភ័ណភាពនៃផលិតផលទាំងនោះ ដោយប្រើប្រាស់ភាជនៈសំរាប់ដាក់ឥវ៉ាន់ ដោយធានាការការពារគុណភាព និងសុវត្ថិភាព

" ការហាលសំងួត " សំដៅដល់បច្ចេកទេសដកទឹកចេញពីវត្ថុធាតុដើម ដោយប្រើប្រាស់ពន្លឺព្រះអាទិត្យចំហាយខ្យល់ក្តៅ ឆ្អើរ ឬ បច្ចេកទេសផ្សេងៗទៀត ដើម្បីរក្សាគុណភាពនិងការរក្សាទុកអោយបានយូរនៃផលិតផលទាំងនោះ

" ការបង្អក " សំដៅដល់បច្ចេកទេសថែរក្សាវត្ថុធាតុដើម ជាពិសេសផលិតផលបសុសត្វ មច្ឆជាតិ ដើម្បីរក្សាគុណភាព និងសុវត្ថិភាព ការរក្សាទុកបានយូរ ដោយសីតុណ្ហភាពត្រជាក់សមស្រប

" ការរក្សាទុក " សំដៅដល់បច្ចេកទេសទុកដាក់វត្ថុធាតុដើម ឬ ផលិតផលកសិកម្មអោយបានយូរពីការខូចខាតដែលបណ្តាលមកពីពពួកសត្វកកេរ ពពួកសត្វល្អិតចង្រៃ មេរោគនានា ក្នុងសីតុណ្ហភាពសមស្រប និងបរិស្ថានល្អ ។ល។

" ផលិតករ " សំដៅដល់អ្នកផលិតចំណីអាហារនៃផលិតផលកសិកម្ម ដូចជា អ្នកដាំដុះ អ្នកចិញ្ចឹមសត្វ វារីវប្បករ អ្នកនេសាទ អ្នកកែច្នៃ ។ល។

" ការចម្លង " សំដៅដល់វត្តមាននៃសារធាតុមិនត្រូវការគ្រប់ប្រភេទចូលទៅក្នុងចំណីអាហារនៃផលិតផលកសិកម្ម

" កំរិតអតិបរមានៃសំណល់សារធាតុបង្កគ្រោះថ្នាក់ " សំដៅដល់វត្តមាននៅក្នុងចំណីអាហារនៃសារធាតុបង្កគ្រោះថ្នាក់លើសពីកំរិតកំណត់ ឬ កំរិតដែលធ្វើឱ្យអាហារមានស្ថានភាពអសុវត្ថិភាពចំពោះអ្នកហូបចុក ។ សារធាតុបង្កគ្រោះថ្នាក់ទាំងនោះអាចជាពពួកជីវសាស្ត្រ សារធាតុគីមី និងពពួករូបសាស្ត្រ

- ជីវសាស្ត្របង្កគ្រោះថ្នាក់ : មានពពួកបាក់តេរី ពពួកផ្សិត ពពួកប៉ារ៉ាស៊ីត ពពួកវ៉ាយរ៉ុស
- សារធាតុគីមីបង្កគ្រោះថ្នាក់ : មានការបំពុលបរិស្ថានដោយសកម្មភាពឧស្សាហកម្ម ប្រព្រឹត្តិកម្ម-អាហារ សារធាតុពុលពីធម្មជាតិនៃអាហារ
- រូបសាស្ត្របង្កគ្រោះថ្នាក់ : មានធូលី កំទេចកញ្ចក់ កំទេចថ្ម កំទេចលោហៈ កំទេចប្លាស្ទិក កំទេចឆ្អឹង កំទេចឈើ . . .

" ចំណីអាហារកសិកម្មនៃផលិតផលកសិកម្មមានសុវត្ថិភាព " សំដៅដល់អាហារដែលបន្ទាប់ពីបានបរិភោគទៅមិនបង្កអោយមានបញ្ហាអាក្រក់ដល់សុខភាពអ្នកប្រើប្រាស់

" ចំណីអាហារនៃផលិតផលកសិកម្មមានគុណភាព " សំដៅដល់អាហារដែលមានវត្តមានអាហាររូបត្ថម្ភ និងមានលក្ខណៈគ្រប់គ្រាន់ទៅនឹងគោលបំណងនៃអាហារនោះ

" បមាណីផលិតផលកសិកម្ម " សំដៅដល់ខ្នាតគំរូផលិតផលកសិកម្មដែលមានលក្ខណៈសំគាល់ទៅលើ វិសាលភាព ការពិពណ៌នា សមាសភាពនឹងកត្តាគុណភាពនៃផលិតផល អនាម័យ ការចម្លង ការវេចខ្ចប់ ស្លាកសញ្ញា និងវិធីសាស្ត្រនៃការវិភាគសំណាកផលិតផល ។

## ជំពូកទី ២

## គោលការណ៍គ្រប់គ្រងសុវត្ថិភាពក្នុងដំណាក់កាលផលិតកម្មកសិកម្ម

**ប្រការ ៤ .-**

គ្រប់ទីកន្លែងនៃផលិតកម្មកសិកម្ម និងមជ្ឈដ្ឋានជុំវិញត្រូវមានអនាម័យល្អ គ្មានជាតិពុល និងធានាគ្មានការ ចម្លង ។

**ប្រការ ៥ .-**

ពូជរុក្ខជាតិ ពូជសត្វ ពូជមច្ឆជាតិ និងសម្ភារៈកសិកម្មដែលបំរើអោយផលិតកម្មកសិកម្មត្រូវអនុវត្ត តាមបមាណីប្រើប្រាស់ដែលអនុញ្ញាតដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**ប្រការ ៦ .-**

រាល់ផលិតកម្មកសិកម្ម ត្រូវអនុវត្តស្របតាមវិធាន នៃកិច្ចប្រតិបត្តិល្អប្រសើរដែលត្រូវកំណត់ដោយគោល ការណ៍ណែនាំរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**ប្រការ ៧ .-**

បុគ្គលដែលចូលរួមក្នុងផលិតកម្មកសិកម្មត្រូវរក្សាអនាម័យចំពោះខ្លួនប្រាណ និងសំលៀកបំពាក់របស់ខ្លួន នៅកន្លែងប្រមូលផលកសិកម្ម និងដឹកជញ្ជូន ។

**ប្រការ ៨ .-**

ការប្រមូលផលកសិកម្មត្រូវអនុវត្តនៅក្នុងដំណាក់កាលដែលផលិតផលមានគុណភាពខ្ពស់ និងនៅពេលដែល ផលិតផលកសិកម្មទាំងនោះផុតកំណត់ឥទ្ធិពលបង្កគ្រោះថ្នាក់នៃសារធាតុបង្កគ្រោះថ្នាក់ដែលបានប្រើក្នុងដំណើរការ ផលិតកម្មកសិកម្ម ។ ហាមឃាត់ការប្រមូលផលចំពោះផលិតផលកសិកម្ម ដែលមិនទាន់ផុតកំណត់ឥទ្ធិពលបង្ក គ្រោះថ្នាក់សម្រាប់ធ្វើជាចំណីអាហាររបស់មនុស្ស ។

## ជំពូកទី ៣
## គោលការណ៍កំណត់ក្នុងដំណាក់កាលកែច្នៃបឋម

**ប្រការ ៩ ._**

គ្រប់ទីកន្លែង និងមជ្ឈដ្ឋានជុំវិញដែលបំរើឱ្យដំណាក់កាលកែច្នៃបឋមនៃផលិតផលកសិកម្ម ត្រូវមានលក្ខណៈបច្ចេកទេសសមស្របដើម្បីធានាឱ្យចំណីអាហារដែលបានកែច្នៃមានអនាម័យ មានគុណភាព និងសុវត្ថិភាព ។

**ប្រការ ១០ ._**

ចំណីអាហារនៃផលិតផលកសិកម្ម ដែលបានធ្វើការកែច្នៃបឋម ត្រូវអនុវត្តតាមវិធីសាស្ត្រកែច្នៃសមស្របតាមលក្ខណៈបច្ចេកទេស ដើម្បីឱ្យចំណីអាហារទាំងនោះ មានអនាម័យ មានគុណភាព និងសុវត្ថិភាព ។

**ប្រការ ១១ ._**

គ្រឿងផ្សំសម្រាប់ប្រើប្រាស់ក្នុងការកែច្នៃផលិតផលកសិកម្មក្នុងដំណាក់កាលកែច្នៃបឋមត្រូវតែរក្សាអនាម័យ គុណភាព និងសុវត្ថិភាព ។

ហាមឃាត់ ដាច់ខាតការប្រើប្រាស់សារធាតុគីមីពុល ឬ សារធាតុផ្សេងទៀតធ្វើជាគ្រឿងផ្សំសម្រាប់កែច្នៃផលិតផលកសិកម្ម ឬ ការរក្សាទុកនូវផលិតផលកសិកម្មទាំងនោះ ដែលអាចនាំមកនូវការប៉ះពាល់ដល់សុខភាពសាធារណៈ ។

**ប្រការ ១២ ._**

មធ្យោបាយដឹកជញ្ជូនចំណីអាហារនៃផលិតផលកសិកម្មក្នុងដំណាក់កាលកែច្នៃបឋមត្រូវគោរពតាមលក្ខណៈបច្ចេកទេសសមស្របដើម្បីធានាឱ្យចំណីអាហារទាំងនោះមានអនាម័យ គុណភាព និងសុវត្ថិភាព ។

**ប្រការ ១៣ ._**

បុគ្គលដែលចូលរួមក្នុងដំណាក់កាលកែច្នៃបឋមនៃផលិតផលកសិកម្មត្រូវរក្សាអនាម័យចំពោះខ្លួនប្រាណ និងសំលៀកបំពាក់របស់ខ្លួននៅកន្លែងកែច្នៃ ។

**ប្រការ ១៤ ._**

ផលិតផលកសិកម្មកែច្នៃបឋមត្រូវរក្សានៅក្នុងកន្លែង ឬ វេចខ្ចប់ដោយប្រើសម្ភារៈវេចខ្ចប់ស្អាត និងមានអនាម័យ ដែលធានាបាននូវគុណភាព និងសុវត្ថិភាពចំណីអាហារ ។

## ជំពូកទី ៤
## ការគ្រប់គ្រង និង ការត្រួតពិនិត្យសុវត្ថិភាពចំណីអាហារនៃផលិតផលកសិកម្ម

**ប្រការ ១៥ .-**

ការត្រួតពិនិត្យសុវត្ថិភាពចំណីអាហារនៃផលិតផលកសិកម្មត្រូវស្ថិតនៅក្នុងដែនសមត្ថកិច្ចទូទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមាននាយកដ្ឋានកសិ-ឧស្សាហកម្មទទួលខុសត្រូវអនុវត្ត ។

**ប្រការ ១៦ .-**

អង្គភាពជំនាញនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានភារៈកិច្ចអនុវត្តបណ្តាវិធានការទាំងឡាយដែលទាក់ទងទៅនឹងការគ្រប់គ្រង ការត្រួតពិនិត្យ និងការលើកកំពស់គុណភាព សុវត្ថិភាព ចំណីអាហារនៃផលិតផលកសិកម្មតាំងពីដំណាក់កាលចាប់ផ្តើមពីផលិតកម្មដំបូងរហូតដល់ដំណាក់កាលចុងក្រោយនៃការកែច្នៃបឋម និងចំណីអាហារនៃផលិតផលកសិកម្មនាំចូល-នាំចេញដែល កំពុងរក្សាទុក ឬកំពុងធ្វើចរាចរចែកចាយនៅក្នុងប្រទេសសំដៅធានាគុណភាពសុវត្ថិភាព និងសម្រាប់សុខភាពសាធារណៈ ។

**ប្រការ ១៧ .-**

សកម្មភាពដែលទាក់ទងទៅនឹងការផលិត ការកែច្នៃបឋម ការនាំចូលនាំចេញ ការរក្សាទុក ឬ កំពុងធ្វើចរាចរត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យដើម្បីផ្ទៀងផ្ទាត់ទៅនឹងកំរិតអតិបរមាសំណល់នៃសារធាតុបង្កគ្រោះថ្នាក់ដើម្បីរកឱ្យឃើញនូវចំណីអាហារនៃផលិតផលកសិកម្មណាដែលមាន ឬ គ្មានគុណភាព សុវត្ថិភាព ។ កំរិតអតិបរមាសំណល់នៃសារធាតុបង្កគ្រោះថ្នាក់ដែលធ្វើឱ្យចំណីអាហារនៃផលិតផលកសិកម្មគ្មានសុវត្ថិភាពត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ ដោយអនុលោមតាមបទដ្ឋានអាស៊ាន និងតាមបទដ្ឋាននៃគណៈកម្មការម្ហូបអាហាររបស់អង្គការស្បៀងអាហារនិងកសិកម្មសហប្រជាជាតិ និងអង្គការសុខភាពពិភពលោក (Codex Alimentarius Commission-CAC) ។

**ប្រការ ១៨ .-**

ការត្រួតពិនិត្យគុណភាព សុវត្ថិភាព ចំណីអាហារនៃផលិតផលកសិកម្ម ត្រូវអនុវត្តដោយមន្ត្រីអធិការកិច្ចចម្រុះដែលត្រូវជ្រើសតាំងដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

មន្ត្រីអធិការចម្រុះត្រួតពិនិត្យសុវត្ថិភាពចំណីអាហារនៃផលិតផលកសិកម្ម មានសមត្ថកិច្ចក្នុងការចុះស៊ើបអង្កេត ស្រាវជ្រាវ និងធ្វើរបាយការណ៍អំពីស្ថានភាព ស្តីពីសុវត្ថិភាពចំណីអាហារនៃផលិតផលកសិកម្ម ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**ប្រការ ១៩ .-**

មន្ត្រីអធិការចម្រុះត្រួតពិនិត្យចំណីអាហារនៃផលិតផលកសិកម្ម មានភារៈកិច្ច :

- សហការជាមួយសមត្ថកិច្ចពាក់ព័ន្ធតាមការចាំបាច់
- ធ្វើអធិការកិច្ចលើចំណីអាហារនៃផលិតផលកសិកម្មដើម្បីផ្ទៀងផ្ទាត់ទៅនឹងស្តង់ដារកំរិតអតិបរមាសំណល់នៃសារធាតុបង្កគ្រោះថ្នាក់ ដូចមានចែងក្នុងប្រការ ១៧
- ត្រួតពិនិត្យចំណីអាហារនៃផលិតផលកសិកម្ម ត្រូវអនុវត្តជាប្រក្រតីតាមផែនការមានពេលវេលាកំណត់ ឬ គ្មានផែនការ ឬ តាមករណីដែលមិនបានគ្រោងទុក ដោយអធិការចម្រុះត្រួតពិនិត្យចំណីអាហារនៃផលិតផលកសិកម្ម
- យកសំណាកចំណីអាហារនៃផលិតផលកសិកម្មទៅធ្វើការវិភាគផ្ទៀងផ្ទាត់ទៅនឹងស្តង់ដារកំរិតអតិបរមាសំណល់នៃសារធាតុបង្កគ្រោះថ្នាក់
- ផ្តល់ដំបូន្មានដល់អ្នកផលិតចំណីអាហារនៃផលិតផលកសិកម្ម ដើម្បីអនុវត្តទៅតាមគោលការណ៍គ្រប់គ្រងសុវត្ថិភាពក្នុងដំណាក់កាលផលិតកម្ម រហូតដល់ដំណាក់កាលចុងក្រោយនៃការកែច្នៃបឋម
- ធ្វើការកត់ត្រា និងធ្វើរបាយការណ៍ស្តីពីអធិការកិច្ចចំណីនៃផលិតផលកសិកម្ម ។

**ប្រការ ២០ .-**

អ្នកប្រើប្រាស់ចំណីអាហារនៃផលិតផលកសិកម្ម ត្រូវបានលើកទឹកចិត្ត និងមានសិទ្ធិរាយការណ៍ជូនអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលនៅជិតបំផុតនូវព្រឹត្តិការណ៍ទាំងឡាយណាដែលជឿជាក់ថាចំណីអាហារផលិតផលកសិកម្មគ្មានសុវត្ថិភាព ឬ ខូចគុណភាព ។

**ប្រការ ២១ .-**

អ្នកផលិតចំណីអាហារនៃផលិតផលកសិកម្ម មានកាតព្វកិច្ចទទួលខុសត្រូវជាចម្បង ក្នុងការធានាចំណីអាហារឱ្យមានគុណភាព សុវត្ថិភាព និងត្រូវសហការជាមួយមន្ត្រីអធិការចម្រុះត្រួតពិនិត្យសុវត្ថិភាពចំណីអាហារនៃផលិតផលកសិកម្ម ដើម្បីសម្រួលការងារអធិការកិច្ច ។

**ប្រការ ២២ .-**

ត្រូវហាមឃាត់ :

- រាល់ការផ្សាយពាណិជ្ជកម្មចំណីអាហារនៃផលិតផលកសិកម្មគ្រប់ប្រភេទដែលមានលក្ខណៈភូតកុហកក្លែងបន្លំ អំពីគុណភាព និងសុវត្ថិភាព លើចំណីអាហារនៃផលិតផលកសិកម្ម ។
- រាល់ការធ្វើពាណិជ្ជកម្មចំណីអាហារនៃផលិតផលកសិកម្ម ដែលខូចគុណភាព ឬ មានជាតិពុល ឬ មិនសមស្រប និងលក្ខណៈវិនិច្ឆ័យគុណភាពសុវត្ថិភាព ។

**ប្រការ ២៣ .-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសិទ្ធិតម្រូវឱ្យធ្វើកិច្ចសន្យាកែតម្រូវ ឬ ចេញលិខិតព្រមាន ជាលាយលក្ខណ៍អក្សរ និងចាត់វិធានការផ្លូវច្បាប់នានា ចំពោះបុគ្គលណាដែលប្រព្រឹត្តផ្ទុយនឹងវិធាននានាដែលមានចែងក្នុងប្រកាសនេះ ។

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

**ប្រការ ២៤ .-**

ប្រកាស ឬ សេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ២៥ .-**

អគ្គនាយកនៃក្រសួង អគ្គាធិការ នាយកខុទ្ទកាល័យរដ្ឋមន្ត្រី គ្រប់ប្រធាននាយកដ្ឋាន គ្រប់ប្រធានអង្គភាពចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងគ្រប់ប្រធានមន្ទីរកសិកម្មខេត្ត-ក្រុង ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០៧

រដ្ឋមន្ត្រី

ចាន់ សារុន

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងសុខាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់សាលាខេត្ត-ក្រុង
- ដូចប្រការ ២៥
- ឯកសារ-កាលប្បវត្តិ